គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សិក្ខាសាលាថ្នាក់ជាតិ
# ស្តីពី
# ការពង្រឹងការអនុវត្តច្បាប់ដើម្បីយុត្តិធម៌ជនរងគ្រោះ

ដោយសម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៦

ម៉ោង ៨.៣០ ព្រឹក

ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ សមាជិក សមាជិកា នៃអង្គសិក្ខាសាលាជាទីគោរព រាប់អាន

ជាបឋម ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយ ដោយបានទទួលនូវវត្តមាន ឯកឧត្តម រដ្ឋមន្ត្រីឯកឧត្តម លោកំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មន្ត្រីជាន់ខ្ពស់ ពីក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធផ្នែកច្បាប់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានមកជួបជុំគ្នាក្នុងសិក្ខាសាលាជាតិ ស្តីពី «**ការពង្រឹងការអនុវត្តច្បាប់ ដើម្បីយុត្តិធម៌ជនរងគ្រោះ**» នាពេលនេះ ។ការរៀបចំសិក្ខាសាលាថ្នាក់ជាតិ ក្នុងថ្ងៃនេះ គឺ ដើម្បីសិក្សាអំពីស្ថានភាពជាក់ស្តែង ដែលមានក្នុងសង្គមកម្ពុជាយើង ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលនៅមិនទាន់មានភាពល្អប្រសើរ អាចឆ្លើយតបទៅនឹងបំណងប្រាថ្នានៃការកសាងច្បាប់នេះ ដែលចង់«បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើននូវសុខភាព សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារលើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តឲ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ការបង្ក្រាប ការផ្តន្ទាទោសការជួញដូរមមនុស្ស ជាពិសេស ស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ឬឧបករណ៍ ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានឲ្យសច្ចាប័ន ឬចុះហត្ថលេខា ។»

យើងនឹងនាំគ្នាសិក្សារកភាពខ្វះចន្លោះក្នុងឯកសារច្បាប់ នីតិវិធី ឬការអនុវត្ត ដែលមិនទាន់អាចឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងបញ្ហាសង្គម ដែលកំពុងតែកើតមានជារៀងរាល់ថ្ងៃ ឲ្យបានថមថយ ឬលុបបំបាត់បាន ។

ពីមួយថ្ងៃទៅមួយថ្ងៃ មានបញ្ហាជាច្រើនដែលលេចចេញជាបញ្ហាសង្គម ដែលទាមទារឲ្យមានដំណោះស្រាយ ។ បញ្ហាខ្លះ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃការដោះស្រាយបញ្ហាចាស់ ដែលមិនបានជ្រះស្រឡះ នៅមានសេសសល់នូវភាពមន្ទិលសង្ស័យ បង្កើតបានជាបញ្ហាថ្មី ដែលកាន់តែស្មុគស្មាញ កាន់តែប្រឈម ហើយប្រជាពលរដ្ឋក៏កាន់តែព្រងើយកន្តើយចំពោះការអនុវត្តច្បាប់ថែមទៀត ។

ជាគោលការណ៍អន្តរជាតិ ក៏ដូចជាក្នុងច្បាប់ជាតិ ជនរងគ្រោះចាំបាច់ត្រូវទទួលបានកិច្ចការពារសមស្របពីរដ្ឋាភិបាល ។ ពួកគាត់មានសិទ្ធិក្នុងការទទួលបាននូវតម្រូវការជាមូលដ្ឋាន ការថែទាំ ការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ការទទួលបានសិទ្ធិក្នុងការរស់នៅប្រកបដោយសុវត្ថិភាព គ្មានការរើសអើង និងត្រូវមានមុខរបរចិញ្ចឹមជីវិតដូចប្រជាពលរដ្ឋដទៃ ជាពិសេសសិទ្ធិក្នុងការទទួលបាននូវការគាំទ្រផ្នែកច្បាប់ ។

ទោះបីជាយ៉ាងនេះក្តី ក្នុងការអនុវត្តច្បាប់ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជនរងគ្រោះជាច្រើន មិនទាន់បានទទួលការគាំពារផ្នែកច្បាប់ពេញលេញនៅឡើយ ព្រោះពួកគាត់មិនដឹងថា ត្រូវធ្វើដូចម្តេចទើបអាចទទួលបានការការពារ ឬជនរងគ្រោះខ្លះ ភ័យខ្លាចការចោទប្រកាន់ត្រឡប់វិញ ព្រោះតែខ្វះភស្តុតាងបញ្ជាក់ ខ្វះសាក្សីគ្រប់គ្រាន់ដើម្បីដាក់បន្ទុកជនល្មើសជាដើម ។ មួយចំនួនមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបន្តនីតិវិធីច្បាប់ដ៏ស្មុគស្មាញ និងការអូសបន្លាយពេលវេលារបស់តុលាការបានឡើយ ព្រោះតែភាពក្រីក្រ ត្រូវការពេលវេលាស្វែងរកមុខរបរ និងប្រាក់ចំណូល ។ ឯខ្លះទៀត យល់ថាមិនមានប្រយោជន៍អ្វីដែលត្រូវចំណាយថវិកា និងពេលវេលាបន្ថែមទៀត ព្រោះតែការរង់ចាំដែលពុំមានលទ្ធផល ក្រៅពីការបង់ខាតនោះទេ ។ ពេលខ្លះ ទោះបីជាចេញសាលក្រមពីតុលាការសម្រេចទោសហើយក្តី ក៏មិនទទួលបានសំណងប៉ះប៉ូវការខូចខាតអ្វីដែរ ហើយជនល្មើស នៅតែអាចប្រព្រឹត្តបទល្មើសបន្តទៀតបានយ៉ាងងងើល ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ប្រជាពលរដ្ឋដែលខ្វះខាត អត់ ឃ្លាន គឺពុំមានដំណោះស្រាយល្អ សម្រាប់ការរស់នៅនោះឡើយ ។ ប្រជាពលរដ្ឋជាច្រើនដែលមានបញ្ហា មិនអាចរកអ្នកជួយបាន ព្រោះគាត់មិនដឹងទាក់ទងអ្នកណាដែលអាចផ្តល់យោបល់ ឬ ណែនាំដើម្បីជួយគាត់ឲ្យអាចដោះស្រាយបញ្ហាជីវភាពរបស់

គាត់បាន ។ ប្រជាពលរដ្ឋជាច្រើន បានស្វែងរកការងារ ឬប្រាក់ចំណូលទាំងប្រថុយប្រថាន ព្រោះតែមិនមានជម្រើសក្នុងការដោះស្រាយ ឬអាស្រ័យដោយមានការអូសទាញពីជនដទៃ ។

ប្រជាពលរដ្ឋទាំងនេះប្រឈមនឹងការលំបាកជាខ្លាំង ។ ពេលគាត់ត្រូវបានគេបោកបញ្ឆោត ឬជួញដូរ ឬកេងប្រវ័ញ្ចឬ ប្រើហិង្សារំលោភបំពាន គាត់ត្រូវការឲ្យសមត្ថកិច្ច ឬអាជ្ញាធរជួយអន្តរាគមន៍ និងត្រូវការឲ្យតុលាការជួយរកយុត្តិធម៌ ។

ប្រជាពលរដ្ឋរងគ្រោះ ត្រូវការជំនួយគាំទ្រ ជាពិសេស សេវាកម្មនានា រួមទាំងជំនួយផ្នែកច្បាប់ ជំនួយផ្នែកសុខភាព ការអប់រំបំណិនជីវិត ការផ្តល់ជំនាញឬគន្លឹះក្នុងការរស់នៅ ជាជម្រើសដើម្បីកុំឲ្យវិលត្រឡប់ទៅរងគ្រោះម្តងទៀត ។

ពួកគាត់ចង់បានការគាំទ្រផ្នែកច្បាប់ តែនីតិវិធីតុលាការមានភាពស្មុគ្រស្មាញ និងអូសបន្លាយ ដែលត្រូវការចំណាយថវិកាជាច្រើនរាប់ទាំងការធ្វើដំណើរចុះឡើងជាច្រើនលើក ច្រើនសារ ការរង់ចាំ ហើយទីបំផុត មានករណីជាច្រើន ដែលរកមិនឃើញកំហុសជនសង្ស័យ ឬបង្វែរបទចោទ ឬត្រូវដោះលែង ព្រោះមិនមានទទ្បីករណ៍គ្រប់គ្រាន់ដើម្បីដាក់បន្ទុកជាដើម ធ្វើឲ្យគាត់អស់សង្ឃឹម និងប្តូរចិត្តមិនចង់ប្តឹងជនល្មើសនិងទ្រាំឈឺចាប់បន្តទៀត ។

បញ្ហាទាំងនេះ បានបង្កើតឲ្យមាននូវការថ្នាំងថ្នាក់ពី ប្រជាពលរដ្ឋរងគ្រោះកាន់តែច្រើនឡើង ដែលទាមទារឲ្យមានការពិនិត្យ និងពិភាក្សាគ្នាឡើងវិញ អំពីបែបបទ នីតិវិធី និងភាពខ្វះចន្លោះនៃបទដ្ឋានច្បាប់ ឬការអនុវត្ត ដែលគប្បីត្រូវកែលម្អជាបន្ទាន់ ដើម្បីជាគន្លឹះដោះស្រាយបញ្ហា និងឆ្លើយតបទៅនឹង ចំណុចខ្វះចន្លោះ និងភាពប្រឈមទាំងឡាយ ដែលនាំឲ្យប្រជាពលរដ្ឋមានកង្វល់ ហើយនៅតែប្រថុយប្រថុយប្រថាននឹងគ្រោះថ្នាក់ជាបន្តបន្ទាប់ មិនអាចបង្ការទប់ស្កាត់បាន ។

អាស្រ័យហេតុនេះ ក្នុងរយៈពេលមួយថ្ងៃនៃសិក្ខាសាលានេះ ខ្ញុំសំណូមពរឲ្យឯកឧត្តម លោក ជំទាវ លោក លោកស្រី ដែលជាមន្ត្រីជំនាញជាន់ខ្ពស់ ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ មេត្តាផ្លាស់ប្តូរយោបល់ឲ្យបានល្អិតល្អន់ អំពីស្ថានភាពជាក់ស្តែងនៃបទល្មើស ការដោះស្រាយវិវាទ និងការផ្តល់សំណងតាមនីតិវិធីរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសក្នុងចំណោមពលករដែលទៅធ្វើការនៅក្រៅប្រទេស ដំណើរការផ្តន្ទាទោសរបស់តុលាការចំពោះ បទល្មើសជួញដូរមនុស្ស ការជួយផ្តល់សេវាផ្នែកសង្គមកិច្ច ដើម្បីឲ្យជនរងគ្រោះទទួលបាន សេវាគាំទ្រផ្នែកច្បាប់ យុត្តិធម៌ និងសំណងបដិទាន បទពិសោធន៍ល្អៗដែលរៀនសូត្របាន ភាពប្រទាក់ក្រឡានៃសេវាកម្ម ភាពប្រឈមក្នុងការអនុវត្ត និងការកំណត់ទិសដៅសកម្មភាពដែល ជាគន្លឹះដោះស្រាយ សម្រាប់ការផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ជាពិសេស ការអនុវត្តនីតិវិធីក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ **ដែលកន្លងមកប្រទេសក្នុងសហគមន៍អាស៊ាន បានបង្កើតឲ្យមានអាជ្ញាធរកណ្តាលសម្រាប់ជាស្ថាប័នបង្គោលសម្រាប់ជួយគ្នាទៅវិញទៅមក**

ក្នុងការដោះស្រាយ និងអនុវត្តច្បាប់រវាងបណ្តាប្រទេសនៅក្នុងតំបន់ ដែលស្ថាប័ននេះចាំបាច់ត្រូវដើរតួនាទីឲ្យបានសកម្មក្នុងការជួយជនរងគ្រោះ ការស្វែងរកបទល្មើស ជនល្មើសដើម្បីផ្តន្ទាទោស ក្នុងគោលដៅកាត់បន្ថយប្រសិទ្ធភាពនៃបទល្មើស និងបន្ថយភាពរងគ្រោះរបស់ប្រជាពលរដ្ឋដែលកំពុងតែព្យាយាមស្វែងរកការងារដែលប្រកបដោយសុវត្ថិភាព ។ នៅមានការងារជាច្រើនទៀតដែលយងត្រូវធ្វើ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប ការពារជនរងគ្រោះ និងផ្តន្ទាទោសជនល្មើស ដែលទាមទារឲ្យមានកិច្ចសហការឲ្យកាន់តែខ្លាំង កាន់តែរឹងមាំ កាន់តែរលូន ឈានទៅបោសសំអាតបទល្មើសពាក់ព័ន្ធ និងត្រូវគ្រប់គ្រងឲ្យបានណែន នូវលំហូរមិនប្រក្រតីនៃជនណាកស្រុក និងទេសន្តរប្រវេសន៍ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគ្រប់ការចូលរួម និងគាំទ្រ ពីបណ្តាដៃគូនានា **ជាក់ស្តែងនៅក្នុងសិក្ខាសាលានេះ មានអង្គការ Cambodia Acts អង្គការ IJM អង្គការរតនៈ អង្គការ UN-ACT ដែលបានសហការជាមួយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រឲ្យមានសិក្ខាសាលាថ្នាក់ជាតិនេះ និងអង្គការជាច្រើនទៀត ដែលបាននិងកំពុង គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រទាំងបួន នៃផែនការជាតិក្នុងដំណើរការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** សូមអរគុណចំពោះវត្តមានដ៏មានសារៈសំខាន់របស់ ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាពិសេសមន្ត្រីក្នុងប្រព័ន្ធយុត្តិធម៌ ពីបណ្តារាជធានីខេត្ត ដែលបានមកចូលរួម យ៉ាងច្រើនកុះករនៅទីនេះ ។

**ខ្ញុំសូមលើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរយោបល់ប្រកបដោយន័យស្ថាបនា ដែលខ្ញុំនឹងរង់ចាំទទួលនូវលទ្ធផលដែលមានចរឹតជាដំណោះស្រាយ និងធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ជនរងគ្រោះគ្រប់រូប ជាពិសេសជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ។**

ខ្ញុំសូមជូនពរដល់អង្គសិក្ខាសាលា ឲ្យទទួលបានជោគជ័យ និង**សូមប្រកាសបើកសិក្ខា**សាលា ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**